SATNET ASIA
បណ្តាញទន់វាត្ថុនសម្រាប់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ

# ប្រព័ន្ធផ្សាំ "Mukibat" សម្រាប់ដាំដំឡូងមី

ឯកសារបច្ចេកវិទ្យា

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

## ចំណុចគន្លឹះ៖

- វិធីសាស្ត្រដាំដំឡូងមីទទួលបានទិន្នផលខ្ពស់។
- ដំឡូងមីផ្សាំអាចដាំនៅក្នុងម្លប់ដែលដំឡូងមីជាទូទៅមិនអាចដាំបាន។
- តម្រូវការកម្លាំងពលកម្មកើនឡើង។

## តើអ្វីជាប្រព័ន្ធផ្សាំ "Mukibat" សម្រាប់ដាំដំឡូងមី?

"Mukibat" គឺជាប្រព័ន្ធផ្សាំដើម្បីផលិតកូនពូជដំឡូងមី។ ប្រព័ន្ធនេះប្រើដំឡូងមីជ័រ (*Manihot glaziovii*) ដែលជាដំឡូងមីមានអាយុលើសពីពីរឆ្នាំជាប្រភេទដំឡូងមីដុះតាមខ្នែងល្អ និងផលិតផលក្នុងស្រុក (*M. esculenta*) សម្រាប់ធ្វើជាដើមផ្សាំ។ ការដាំតាមបច្ចេកវិទ្យានេះអាចទទួលបានទិន្នផលពី ៨០ ទៅ ១០០តោនក្នុងមួយហិកតា។ ផលរបរអាចកើនឡើងទោះបីជាចំណាយផលិតកម្មកើនឡើងខ្ពស់ជាងមុនក៏ដោយ។

**រូបភាពទី១៖ អ្នកស្រាវជ្រាវមកពី ILETRI និងកសិករកំពុងប្រមូលផលដំឡូងមី Mukibat**


រូបថត៖ **Ministry of Agriculture, Indonesia**

## ប្រវត្តិ

- បច្ចេកវិទ្យានេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៥២ ដោយកសិករម្នាក់ឈ្មោះថា Mukibat រស់នៅក្នុងស្រុក Kediri កោះជ្វាខាងកើតប្រទេសឥណ្ឌូនេស៊ី (IDRC ១៩៧៨) ដើម្បីបង្កើនផលិតភាពដំឡូងមី។
- ការអភិវឌ្ឍ និងការផ្សព្វផ្សាយបច្ចេកវិទ្យានេះមានលក្ខណៈយឺតយ៉ាវខ្លាំង។ ការសាកល្បងធ្វើឡើងដោយកសិករដែលមានផ្ទៃដីដាំដុះ តិចតួច និងគាំទ្រដល់ការស្រាវជ្រាវ។
- ការសិក្សាថ្មីៗបានបង្ហាញថាកសិករមួយចំនួននៅតែដាំដំឡូងមី Mukibat ដោយសារឧស្សាហកម្មដាំដំឡូងមីក្នុងប្រទេសឥណ្ឌូនេស៊ី មានការកើនឡើង។

## កន្លែងអនុវត្តបច្ចេកវិទ្យា

- ដំឡូងមីMukibatដុះល្អនៅក្នុងបរិស្ថានម្លប់មធ្យមដែលដំឡូងមីធម្មតាមិនអាចមានមើម។
- លក្ខខណ្ឌអាកាសធាតុ៖
  - កម្ពស់៖ ចាប់ពី ១០ ដល់ ៧០០ម៉ែត្រលើកម្រិតនីវ៉ូទឹកសមុទ្រ
  - ភ្លៀង៖ ចាប់ពី ១.៥០០ ដល់ ២.៥០០មីលីម៉ែត្រក្នុងមួយឆ្នាំ
  - សីតុណ្ហភាពអប្បបរមា៖ ១០អង្សាសេ
  - សំណើម៖ ចាប់ពី ៦០ ដល់ ៦៥ភាគរយ
  - ពន្លឺព្រះអាទិត្យ៖ ១០ម៉ោងក្នុងមួយថ្ងៃ
- ដីភាគច្រើនអាចប្រើប្រាស់សម្រាប់ការផលិតប៉ុន្តែគួរមានកម្រិត pH ចាប់ពី ៥,៥ ទៅដល់ ៧។
- ការដាំដំឡូងមីMukibatទទួលបានជោគជ័យក្នុងស្រុកមួយចំនួននៃប្រទេសឥណ្ឌូនេស៊ី។
- កសិករជោគជ័យគឺជាកសិករដែលមានប្រាក់គ្រប់គ្រាន់ដើម្បីបន្តដាំដំឡូងមី និងរស់នៅក្បែរទីផ្សារ។

## ទិដ្ឋភាពបច្ចេកទេស[១]

- បច្ចេកវិទ្យារួមមាន៖
  - ខ្នែងដំឡូងមី-ដំឡូងមីដើម ដើមកៅស៊ូ (*Manihot glaziovii*)
  - មើម-ប្រភេទដំឡូងមី *M. esculenta* ល្អ ឬនៅក្នុងស្រុក
  - ដោតដើមឬស្សីដើម្បីពង្រឹងការផ្សាំ
  - ប្រើប្លាស្ទិកដើម្បីខ្ចប់តំណភ្ជាប់
  - ធ្វើរោងដាក់កូនដំឡូងមី
- វត្ថុធាតុសម្រាប់ដាំគួររៀបចំនៅរដូវប្រាំង និងត្រៀមដាំនៅដើមរដូវវស្សា។
- មើមដំឡូងមីដើមមានប្រវែងប្រហែលពី ១០ ទៅ ៣០សង់ទីម៉ែត្រត្រូវផ្សាំមែកដំឡូងមីធម្មតា (*M. esculenta*) ប្រវែងពី ២០ ទៅ ៧០សង់ទីម៉ែត្រ។ នៅពេលមើមមានប្រវែង (ធំជាង ៤០សង់ទីម៉ែត្រ មើមទាំងនេះអាចយកទៅដាំជាថ្មីដោយផ្ទាល់នៅរដូវដាំទីពីរ ឬទីបី ក្រោយពេលប្រមូលផលរួច (de Foresta *et al.*, ១៩៩៤)។ អង្កត់ផ្ចិតភ្នែក និងដើមផ្សាំត្រូវមានទំហំដូចគ្នាប្រហែលពី ២ ទៅ ៤សង់ទីម៉ែត្រ។ កាត់ភ្នែក និងដើមផ្សាំជារាងបញ្ឆិត។
- ដាក់ចំណិតឬស្សីស្តើងៗនៅក្នុងបណ្តូលផ្នែក និងដើមផ្សាំដើម្បីឲ្យភ្ជាប់គ្នាបានល្អរួចភ្ជាប់មែកទាំងពីរ។ បន្ទាប់មកចងខ្សែប្លាស្ទិក ឬខ្សែ ស្រទបចេកនៅជុំវិញមែកតភ្ជាប់ដើម្បីកុំឲ្យរបូត។ ដាក់ចំណិតឬស្សីស្តើងៗនៅក្នុងបណ្តូលផ្នែក និងដើមផ្សាំដើម្បីឲ្យភ្ជាប់គ្នាបានល្អរួចភ្ជាប់មែកទាំងពីរ។ បន្ទាប់មកចងខ្សែប្លាស្ទិក ឬខ្សែ ស្រទបចេកនៅជុំវិញមែកតភ្ជាប់ដើម្បីកុំឲ្យរបូត។

[១]ប្រសិនមានការលើកឡើងផ្សេងពីនេះមានន័យថាការពណ៌នានេះផ្អែកតាម de Bruin និងGuritno (១៩៨៨)។

- ទុកកំណាត់ដើមនៅក្នុងម្លប់ ដោយស្រោចទឹកជាប្រចាំ។ ប្រហែលប្រាំបីថ្ងៃក្រោយមក ពន្លកចាប់ផ្តើមដុះ។ កាត់យកពន្លកចេញពីដើមផ្សាំប៉ុន្តែ ទុកឲ្យពន្លកចេញនៅលើភ្នែក។
- យកកំណាត់ដើមផ្សាំដាក់ដាំក្នុងដី នៅពេលដែលពន្លកដុះចេញពីភ្នែកមានប្រវែង ប្រហែល ២សង់ទីម៉ែត្រ។
- រៀបចំរណ្តៅជម្រៅ ០,៥ម៉ែត្រ (១x១ម៉ែត្រ និងលុបដីមានលាយរូបធាតុសរីរាង្គ រួមមាន ស្លឹកចេក កាលសំណល់ផ្ទះបាយដែលមានទម្ងន់ចាប់ពី ៥ ទៅ ២៥គីឡូក្រាម។ ដាក់បញ្ឈរកំណាត់ដើមដំឡូង ដោយដាក់មួយកំណាត់ក្នុងមួយរណ្តៅ រួចលុបដីពូននៅជុំវិញកំណាត់ ដើមដំឡូង។
- ថៃទាំកូនផ្សាំ។ កូនផ្សាំអាចដោតឬស្សីទប់។
- កូនផ្សាំជាទូទៅ មានទំហំ ១,២៥x១,៥០ម៉ែត្រប៉ុន្តែទំហំនេះអាចខុសគ្នាជាពិសេសនៅពេល ដាំដើមខុសៗគ្នាជាមួយគ្នា។
- ដំណាំអាចមានរយៈពេលខុសគ្នាចាប់ពី៨ទៅ១៨ខែ។កសិករភាគច្រើនប្រមូលផលនៅក្នុងរយៈពេលពី១១ទៅ១២ខែក្រោយពេលដាំ ចំនួនម្តងក្នុងមួយឆ្នាំ។ មើមចាស់អាចមានសរសៃច្រើននិងរឹង ស្ទើរក្លាយជាឈើដែលមិនអាចយកទៅប្រើការកើត។
- ដើមផ្សាំអាចប្រើម្តងទៀតនៅឆ្នាំទីពីរឬទីបី។ បច្ចេកវិទ្យានេះអាចប្រើរយៈពេល ៣៦ខែ ដោយប្រមូលផលបាន ៣ដង។
- កូនទីពីរនិងទីបីនឹងកាត់បន្ថយការចំណាយលើកូនដោយសារកូនទាំងនេះអាចបានមកពីការប្រមូលផលលើកទី១និងទី២ (គ្រាប់ពូជ Randan)។

## ទិដ្ឋភាពសេដ្ឋកិច្ច

- ការវិនិយោគក្នុងមួយហិកតាប្រមាណ១២.០០០.០០០Rp (១.២៣២ដុល្លារអាមេរិក)។ ការដាំដំណាំដំឡូងមីធម្មតាត្រូវវិនិយោគស្ទើរតែដូចគ្នា (ពី១.១០០ ដល់ ១.២០០ដុល្លារអាមេរិក)[២]ប៉ុន្តែទទួលបាន ទិន្នផលតិចជាង។
- ការសាកល្បងថ្មីៗនៅក្នុងប្រទេសឥណ្ឌូនេស៊ី Mukibat បានទិន្នផលពី ៩០ ទៅ ១០០តោន ក្នុងមួយហិកតា បើប្រៀបធៀបជាមួយដំឡូងមីធម្មតាពី ៥៤ ទៅ ៦២តោន ក្នុងមួយហិកតា (Radjit និង Prasetiaswati ២០១១)។
- ទិន្នផលជាមធ្យមនៅក្នុង MuliaBakti (ប្រទេសឥណ្ឌូនេស៊ី) មានមើម ៣០គីឡូក្រាមក្នុងកូនផ្សាំមួយបើប្រៀបធៀបជាមួយកូនមិនផ្សាំពី ៥ ទៅ ១០គីឡូក្រាម (de Foresta *et al.*, ១៩៩៨)។ De Foresta *et al.*, (១៩៩៨) បានវាយតម្លៃទិន្នផលពី ៦០ ដល់ ១៥០ តោន ក្នុងមួយហិកតារបស់ដំឡូងមី Mukibat តាមសួនបន្លែតាមផ្ទះធៀបនឹង៣ ទៅ ១៥តោន សម្រាប់ដំឡូងមីធម្មតាក្នុងចំការកសិដ្ឋានតូច។
- បរិមាណម្សៅដំឡូងមី Mukibat បានថយចុះពី០,៧ដល់២,២ភាគរយបើប្រៀបធៀបជាមួយដំឡូងមីធម្មតា (Radjit និង Prasetiaswati ២០១១)។
- បច្ចេកវិទ្យានេះត្រូវបានណែនាំឲ្យប្រើប្រាស់នៅលើដីវាលឬសួនបន្លែតាមផ្ទះលើសពីមួយហិកតា។

## ទិដ្ឋភាពបរិស្ថាន

- ជាទូទៅដំឡូងមីមិនត្រូវការប្រព័ន្ធស្រោចស្រពឡើយហើយអាចជាដំណាំរំពឹងលើទឹកភ្លៀង។
- ដំឡូងមី Mukibat ត្រូវការទឹកគ្រប់គ្រាន់នៅពេលដាំដំបូងដូច្នេះដំណាំនេះគួរដាំនៅដើមរដូវវស្សា។

## ទិដ្ឋភាពសង្គម

- ការដាំដំឡូងមីដោយការផ្សាំទាមទារឲ្យធ្វើការងារច្រើនជាងការដាំដំឡូងមីដោយមិនផ្សាំ។ កត្តានេះផ្តល់ឱកាសការងារនៅក្នុងតំបន់ដែលមានតម្រូវការដំឡូងមីផ្សាំខ្ពស់។ ការងារនេះត្រូវចំណាយ រយៈពេលពីរសប្តាហ៍សម្រាប់ការរៀបចំកូនពូជ និងមួយថ្ងៃសម្រាប់ការដាំ។
- ការរៀបចំកូនត្រូវការមនុស្សពីរនាក់ (ប្រុសឬស្រី)។
- ជាទូទៅមនុស្ស១០នាក់ត្រូវធ្វើការរយៈពេលពី៣ទៅ៤ថ្ងៃនៅពេលដាំ និងប្រមូលផលនៅលើផ្ទៃដី១ហិកតា។ ជាធម្មតាបុរសជាអ្នកធ្វើការងារនេះ។
- នៅក្នុងប្រទេសឥណ្ឌាកម្លាំងពលកម្មសម្រាប់ដាំដំឡូងមី Mukibat មានស្ត្រី៣០ភាគរយ និងបុរស៧០ភាគរយ។

**តារាង១៖ប្រាក់ចំណេញដុលក្នុងមួយហិកតាដាំចាប់ពី ៤.០០០ ទៅ ៤.៥០០ដើម**

| ស្រុក | តម្លៃដុល ជាRp (០០០) ($) | ចំណាយប្រែប្រួល ជា Rp (០០០) ($) B | ប្រាក់ចំណេញដុល ជា Rp (០០០) ($) A-B | អត្ថប្រយោជន៍/អត្រាចំណាយ B/C |
|---|---|---|---|---|
| Banyuwangi | 32.450 *(3.33)* | 8.116 *(0.83)* | 24.334 *(2.50)* | 3.00 |
| Trenggalek-1 | 24.264 *(2.49)* | 4.720 *(0.48)* | 19.544 *(2.00)* | 4.10 |
| Trenggalek-2 | 28.080 *(2.88)* | 5.471 *(0.56)* | 22.609 *(2.32)* | 4.13 |
| Pacitan | 10.292 *(1.06)* | 2.803 *(0.29)* | 7.489 *(0.77)* | 2.67 |
| Wonogiri | 14.400 *(1.48)* | 6.373 *(0.65)* | 8.027 *(0.82)* | 1.26 |
| Lampung ខាងកើត | 11.760 *(1.21)* | 5.703 *(0.59)* | 6.057 *(0.62)* | 1.06 |
| Lampung កណ្តាល | 32.472 *(3.33)* | 12.776 *(1.31)* | 19.694 *(2.02)* | 1.54 |

ចំណាំ៖ ចំណាយប្រែប្រួលរួមមាន៖ ដីកូនពូជជី (សរីរាង្គ និងមិនសរីរាង្គ) ការភ្ជួររាស់ការដាំការលើកដី និងជម្រះស្មៅការប្រមូលផល និងដឹកជញ្ជូន។ ចំណាយលើកម្លាំងពលកម្មរួមមានប្រមាណ ៤០.០០០Rp ម្នាក់ក្នុងមួយថ្ងៃ(៤,១១ដុល្លារអាមេរិកម្នាក់ក្នុងមួយថ្ងៃ)
ប្រភព៖ Prasetiaswati *et al.* (២០០៨ និង ២០០៩)

[២] ការបំលែងដោយផ្អែកលើអត្រាប្តូរប្រាក់ OANDA នៅត្រឹមថ្ងៃទី៣១.០៣.២០១៣។

## បញ្ហាក្នុងការចម្លងយកទៅអនុវត្ត

- ត្រូវការជំនាញផ្សាំ។
- កង្វះមូលធនសម្រាប់ទិញមើមផ្សាំ។
- បញ្ហាកម្លាំងពលកម្មនៅពេលផ្សាំ និងដាំ។

## ទំនាក់ទំនង

សាស្ត្រាចារ្យ N. Benkeblia សកលវិទ្យាល័យ West Indies, Mona, Jamaica៖ ទូរស័ព្ទ៖ +១ ៨៧៦៩៧០៦៨៨៩។
អ៊ីមែល៖ noureddine.benkeblia@uwimona.edu.jm

## ឯកសារយោង


- De Bruin, G.H., និង B. Guritno (១៩៨៨)។ ការសាកល្បងរបស់កសិករជាមួយដំណាំដំឡូងមីក្នុងប្រទេសឥណ្ឌូនេស៊ី។ ព្រឹត្តិប័ត្រព័ត៌មាន ILEIA វ៉ុល ៤ លេខ១ pp. ១៤-១៥។ មាននៅវែបសាយត៍៖ ttp://staff.unila.ac.id/bungdarwin/files/2012/07/mukibat-system.pdf
- De Foresta, H., A. Basri, និង Wiyono (១៩៩៤)។ សមាគមបង្កាត់កសិរុក្ខកម្ម។ ដំឡូងមី និងសួនបន្លែនៅផ្ទះល្អ៖ បច្ចេកទេស Mukibat។ កសិរុក្ខកម្មថ្ងៃនេះ វ៉ុល ៦ លេខ១ pp.១២-១៤។
- មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (១៩៧៨)។ ដំឡូងមី (ប្រទេសឥណ្ឌូនេស៊ី៖ ការវាយតម្លៃ។ មាននៅវែបសាយត៍៖ ttp://idl-bnc.idrc.ca/dspace/bitstream/10625/7505/1/67686.pdf
- បន្លែអន្លក់ឥណ្ឌូនេស៊ី និងវិទ្យាស្ថានស្រាវជ្រាវដំណាំមើម (២០០៩)។ លទ្ធផលសំខាន់នៃការសិក្សាគ្រាប់ផ្លែឈើ និងដំណាំមើម ឆ្នាំ២០០៨។ Balitkabi Malang។
- Nugroho, J.H., និងផ្សេងទៀត (១៩៨៥)។ បច្ចេកវិទ្យាដំណាំដំឡូងមីតែមួយមុខ និងដំណាំចម្រុះគ្នា។ ដំណើរការនៃការអភិវឌ្ឍដំឡូងមីនៅថ្នាខាងកើត មជ្ឈមណ្ឌលស្រាវជ្រាវដំឡូងមី UB roots IDRC, Ford Foundation IDC, pp ១៨១-២០០។
- Prasetiaswati, N., និងផ្សេងទៀត (២០០៨)។ ប្រព័ន្ធដំណាំដំឡូងមីមានគុណភាព mukibat៖ ករណីសិក្សាក្នុងខេត្តជ្វាខាងកើត។ ការអភិវឌ្ឍទស្សនៈគ្រាប់ផ្លែឈើ និងដំណាំមើមតាមបែបកសិកម្មនៅជ្វាកណ្តាល ការរៀបចំសិក្ខាសាលាថ្នាក់ជាតិអំពីការអភិវឌ្ឍបន្លែអន្លក់ និងដំណាំមើម ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ S. Nasir និងផ្សេងទៀត។ Surakarta៖មហាវិទ្យាល័យ Agriculture Univ. Sebelas Maret Surakarta វិទ្យាស្ថានវាយតម្លៃសម្រាប់បច្ចេកវិទ្យាកសិកម្ម (AIAT) នៃជ្វាកណ្តាល ILETRI Malang (Cop)។
- Prasetiaswati, N., និងផ្សេងទៀត (២០០៩)។ វាយតម្លៃលទ្ធភាពប្រព័ន្ធដំណាំដំឡូងមី Mukibat នៅកម្រិតកសិដ្ឋាន ករណីសិក្សានៅជ្វា និង Lampung, ១៣ pp។
- Radjit, B.S., និង N. Prasetiaswati (២០១១)។ ទិន្នផលមើម និងបរិមាណម្សៅរបស់ដំឡូងមីប្រភេទមួយចំនួនតាមប្រព័ន្ធផ្សាំ (Mukibat)។ ដកស្រង់ជាភាសាអង់គ្លេស។ J. Agrivigor វ៉ុល ១០ លេខ ២ pp.១៨៥-១៩៥។


## បណ្តាញសំខាន់ៗ

បន្លែអន្លក់ឥណ្ឌូនេស៊ី និងវិទ្យាស្ថានស្រាវជ្រាវដំណាំមើម (ILETRI) (២០១២)។ ទិន្នន័យដំឡូងមីដែលដាំដោយប្រើប្រព័ន្ធ Mukibat។ មាននៅវែបសាយត៍៖

- http://balitkabi.litbang.deptan.go.id/en/index.php/research-highlight/cassava/968-cassava-cultivation-technology
- http://balitkabi.litbang.deptan.go.id/info-teknologi/834-potensi-peningkatan-hasil-ubikayu-melalui-sistem-sambung-mukibat.html

## ឯកសារបច្ចេកវិទ្យាកសិកម្មអាស៊ី SATNET

ឯកសារនេះផ្ដល់ជូនព័ត៌មានអំពីបច្ចេកវិទ្យាកសិកម្មប្រកបដោយនិរន្តភាព ឬ ទម្លាប់អនុវត្តល្អប្រសើរ ដែលបានបង្ហាញសក្ដានុពលរបស់ខ្លួនក្នុងការលើកកម្ពស់ប្រសិទ្ធភាពធនធានផ្ដល់អត្ថប្រយោជន៍សេដ្ឋកិច្ច និងមានផលរំខានតិចតួចចំពោះសង្គម។ ឯកសារនេះគឺជាលទ្ធផលនៃការងារវិភាគដែលធ្វើឡើងដោយបណ្ដាញផ្ទេរចំណេះដឹងអំពីបច្ចេកវិទ្យាកសិកម្មប្រកបដោយនិរន្តរភាព និងបណ្ដាញទីផ្សារកាន់តែប្រសើរនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ (SATNET Asia)។ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកចូលរួមមកពី SATNET Asia មជ្ឈមណ្ឌលសន្តិសុខស្បៀង (FSC) នៃសកលវិទ្យាល័យ Hohenheim ប្រទេសអាល្លឺម៉ង់បានដឹកនាំការបង្កើតក្របខ័ណ្ឌវិភាគដើម្បីវាយតម្លៃនិរន្តរភាព និងផលិតភាពដោយលើកកម្ពស់សក្ដានុពលជម្រើសបច្ចេកវិទ្យាកសិកម្មដោយផ្អែកលើការពិនិត្យមើលយ៉ាងម៉ត់ចត់លើចំណេះដឹងវិទ្យាសាស្ត្រ។ ឧទាហរណ៍នៃជម្រើសបច្ចេកវិទ្យាត្រូវបានប្រមូលពីប្រភពផ្សេងៗជាច្រើនរួមទាំងអ្នកចូលរួមមកពី SATNET Asia ជំនាញការមកពីខាងក្រៅតំបន់ និងច្រកចំណេះដឹងតាមអ៊ីនធឺណិតព្រមទាំងឯកសារផ្សេងៗ។
សម្រាប់បច្ចេកវិទ្យាដែលអាចរកបានព័ត៌មានគ្រប់គ្រាន់ក្របខ័ណ្ឌវិភាគត្រូវបានប្រើប្រាស់ដើម្បីគណនាសូចនាករនិរន្តរភាពសម្រាប់បច្ចេកវិទ្យានេះ។

## អំពីSATNET Asia

SATNET Asia គឺជាបណ្ដាញដែលផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប។ បណ្ដាញនេះត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលកាត់បន្ថយភាពក្រីក្រតាមរយៈកសិកម្មនិរន្តរភាព (CAPSA) នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) ដោយសហការជាមួយមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (APCTT), AVRDC មជ្ឈមណ្ឌលបន្លែពិភពលោកមជ្ឈមណ្ឌលសន្តិសុខស្បៀង (FSC) នៃសកលវិទ្យាល័យ Hohenheim ព្រមទាំងផ្នែកពាណិជ្ជកម្ម និងវិនិយោគនៃ UNESCAP។

SATNET Asia ត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ២០១២ ដើម្បីគាំទ្រដល់គំនិតច្នៃប្រឌិតដើម្បីកសិកម្មប្រកបដោយនិរន្តភាពតាមរយៈការពង្រឹងកិច្ចពិភាក្សាត្បូង-ត្បូង និងការសិក្សាទូទាំងតំបន់។ ដោយធ្វើប្រតិបត្តិការនៅក្នុងប្រទេសចំនួន១០នៃតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ SATNET ធ្វើការសម្របសម្រួលការផ្ទេរចំណេះដឹងតាមរយៈការបង្កើតកម្រងឯកសារអនុវត្តល្អប្រសើរបំផុតអំពីកសិកម្មប្រកបដោយនិរន្តរភាពការសម្របសម្រួលពាណិជ្ជកម្ម និងការចែករំលែកចំណេះដឹងប្រកបដោយភាពច្នៃប្រឌិត។ ដោយផ្អែកលើចំណេះដឹងដែលបានចងក្រងជាឯកសារនេះ SATNET Asia ផ្ដល់កម្មវិធីកសាងសមត្ថភាពដល់អ្នកចូលរួមបណ្ដាញដែលដើរតួនាទីជាភ្នាក់ងារ និងអ្នកច្នៃប្រឌិតផ្លាស់ប្ដូរដូចជាអង្គការកសិករពាណិជ្ជករវិស័យឯកជនវិស័យសាធារណៈ និងអ្នកបង្កើតគោលនយោបាយ។ ការអនុវត្តនេះនឹងអាចឲ្យអ្នកចូលរួមធ្វើការផ្ទេរចំណេះដឹងនេះទៅអ្នកដែលត្រូវការបំផុតពោលគឺកសិករដែលមានផ្ទៃដីដាំដុះតូច និងសហគ្រាសខ្នាតតូច។

ដោយសារវិស័យសាធារណៈលែងគ្របដណ្ដប់លើកិច្ចការអភិវឌ្ឍកសិកម្ម SATNET មានគោលបំណងច្បាស់លាស់ក្នុងការដាក់បញ្ចូលក្រុមដូចខាងក្រោម នៅក្នុងដំណើរការច្នៃប្រឌិតៈ សាកលវិទ្យាល័យក្រុមហ៊ុនឯកជនដែលបង្កើត និងលក់ផលិតផលបច្ចេកវិទ្យាឬផ្ដល់សេវាសម្របសម្រួលពាណិជ្ជកម្មមូលនិធិកសិកម្មអង្គការកសិករ និងអង្គការមិនមែនរដ្ឋាភិបាល។ រួមជាមួយក្រុមគោលដៅទាំងនេះគម្រោងមានគោលដៅបង្កើតបរិយាកាសចំណេះដឹងដែលផ្ដោតលើការកាត់បន្ថយភាពក្រីក្រ និងមានលក្ខណៈអំណោយផលចំពោះការច្នៃប្រឌិតជាប្រចាំ និងប្រកបដោយនិរន្តរភាព។

**SATNET Asia**
CAPSA-ESCAP
Jl. Merdeka 145
Bogor 16111, ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ៖ +62 251 8343277, 8356813
ទូរសារ៖ +62 251 8336290
អ៊ីមែល៖ satnet@satnetasia.org
**www.satnetasia.org**

គម្រោងនេះផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប

ឯកសារបោះពុម្ពផ្សាយនេះរៀបចំឡើងក្រោមជំនួយរបស់សហភាពអឺរ៉ុប។ ខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយនេះ នឹងមានការទទួលខុសត្រូវទាំងស្រុងពី ESCAP ហើយអាចចាត់ទុកថាជាការឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហភាពអឺរ៉ុបមិនថានៅក្នុងស្ថានភាពណាឡើយ។